# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ:** ៥១៧ **គ.ជ.ប**

## ជម្រាបជូន
## លោក លោកស្រី ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត

**កម្មវត្ថុ** : អំពីការផ្តល់កិច្ចសហការ និងជួយសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ឱ្យបង្កលក្ខណៈងាយស្រួលដល់អង្គការខុមហ្វ្រែល ក្នុងការចុះធ្វើសវនកម្មលើបញ្ជីបោះឆ្នោត ឆ្នាំ២០១៩ ។

**យោង** : លិខិតលេខ ៨៨/១៩ គបសយ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ របស់អង្គការខុមហ្វ្រែល។

តបតាមកម្មវត្ថុ និងយោងខាងលើ **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)** សូមជម្រាប **លោក លោកស្រី** ជ្រាបថា អង្គការខុមហ្វ្រែលនឹងធ្វើសវនកម្មលើបញ្ជីបោះឆ្នោត ឆ្នាំ២០១៩ ក្នុងគោលបំណងស្វែងរកឈ្មោះសួន និងវាយតម្លៃគុណភាពបញ្ជីបោះឆ្នោត ឆ្នាំ២០១៩ ដោយចាប់ផ្តើមពីខែសីហា ដល់ខែតុលា ឆ្នាំ២០១៩ ។ ដើម្បីបង្កលក្ខណៈងាយស្រួលឱ្យដំណើរការនេះប្រព្រឹត្តទៅបានដោយរលូន សូម **លោក លោកស្រី** ប្រធានលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ផ្តល់កិច្ចសហការដល់អង្គការខុមហ្វ្រែល និងជួយសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន ដល់ដំណើរការនេះ។

អាស្រ័យហេតុនេះ សូម **លោក លោកស្រី** ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូម **លោក លោកស្រី** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ថ្ងៃ ចន្ទ ៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១៩

**គ.ប គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

**ទេព នីថា**

**ចម្លងជូន:**
- ក្រសួងមហាផ្ទៃ
- រដ្ឋបាលរាជធានី ខេត្ត "ដើម្បីជូនជ្រាប និងផ្តល់កិច្ចសហការ"
- ឯកសារ-កាលប្បវត្តិ